actionaid

# ការជម្រុញប្រព័ន្ធប្រកាសឱ្យដឹងមុននៅប្រទេសកម្ពុជា

*ព័ត៌មានសង្ខេបអំពីគម្រោង*

## បញ្ហាប្រឈម

ប្រព័ន្ធប្រកាសឱ្យដឹងមុននៅក្នុងប្រទេសកម្ពុជាដែលជាប្រទេសងាយរងគ្រោះទៅនឹងគ្រោះមហន្តរាយ មិនទាន់ត្រូវបានធ្វើបច្ចុប្បន្នភាព និងមិនទាន់មានភាពទូលំទូលាយនៅឡើយ ដែលជាហេតុធ្វើឱ្យសហគមន៍មិនអាចសម្របខ្លួនបានគ្រប់គ្រាន់ និងឆ្លើយតបទៅនឹងគ្រោះមហន្តរាយដែលកើតមានដោយបម្រែបម្រួលអាកាសធាតុ។

## ការពិពណ៌នាពីគម្រោង

គម្រោងនេះមានគោលបំណងបង្កើតប្រព័ន្ធប្រកាសឱ្យដឹងមុនដែលអាចដំណើរការបាននៅក្នុងប្រទេសកម្ពុជាដោយមានការសម្របសម្រួល និងការគាំទ្រយ៉ាងរឹងមាំពីក្រសួងពាក់ព័ន្ធរបស់រដ្ឋាភិបាល ដើម្បីធានាបាននូវការប្រកាសឱ្យដឹងមុនអំពីហានិភ័យគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាពទៅដល់ប្រជាសហគមន៍ដែលរស់នៅក្នុងតំបន់ដែលងាយរងគ្រោះដោយគ្រោះមហន្តរាយ។

### តំបន់គោលដៅ

ចំនួន១១ខេត្ត



### ក្រុមគោលដៅ៖

**៣៧១** រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល

**១៤៥,000** អ្នកភ្ជាប់ប្រព័ន្ធប្រកាសឱ្យដឹងមុន

**៥៨១,000** អ្នកទទួលផលដោយប្រយោល

### ព័ត៌មានអំពីការវាស់កម្ពស់ទឹកក្រោមដី

| | |
|---|---|
| ដំឡើងឧបករណ៍វាស់កម្ពស់ទឹកក្រោមដីថ្មីចំនួន | 12 |
| ដំឡើងឧបករណ៍វាស់កម្ពស់ទឹកជំនន់ចំនួន | 6 |
| ផ្លាស់ប្តូរឧបករណ៍វាស់កម្ពស់ទឹកក្រោមដីចំនួន | 20 |

### រយៈពេលអនុវត្តគម្រោង

ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៥

### ថវិកាគម្រោងសរុប

£ ៣៧៦,១៧៦

### សហការអនុវត្តគម្រោងដោយ៖

actionaid

### ឧបត្ថម្ភថវិកាដោយ៖

GSMA

UK International Development

Partnership | Progress | Prosperity

# សកម្មភាព

**១**

គាំទ្រក្រសួងអភិវឌ្ឍន៍ជនបទ និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្នុងការដំឡើងថ្មី និងថែទាំឧបករណ៍វាស់កម្ពស់ទឹកក្រោមដី និងលើដីដែលមានស្រាប់

**២**

បង្កើត និងដាក់ឱ្យដំណើរការប្រព័ន្ធប្រកាសឱ្យដឹងមុន១២៩៤នៅក្នុងខេត្តគោលដៅថ្មីដែលងាយរងគ្រោះដោយគ្រោះមហន្តរាយ ជាមួយអ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

**៣**

រគូបណ្តុះបណ្តាលជាមួយក្រសួងអភិវឌ្ឍន៍ជនបទ និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដល់អង្គការដៃគូនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្តីពីប្រព័ន្ធប្រកាសឱ្យដឹងមុន ១២៩៤ រួមទាំងចំណុចបង្កគ្រោះរាំងស្ងួត និងការផ្ញើសារឱ្យដឹងមុន

**៤**

បង្កើនការយល់ដឹង និងផ្សព្វផ្សាយប្រព័ន្ធប្រកាសឱ្យដឹងមុន ១២៩៤ ក្នុងចំណោមក្រុមងាយរងគ្រោះនៅក្នុងខេត្តដែលងាយរងគ្រោះដោយគ្រោះមហន្តរាយ តាមរយៈព័ត៌មាន ការអប់រំ និងទំនាក់ទំនង និងប្រព័ន្ធផ្សព្វផ្សាយសង្គម

**៥**

រៀបចំកិច្ចប្រជុំសម្របសម្រួលជាមួយភាគីពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងអង្គការដៃគូក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធស្តីពីប្រព័ន្ធប្រកាសឱ្យដឹងមុន និងវេទិកាមនុស្សធម៌

**៦**

ចូលរួមក្នុងវេទិកា និងបណ្តាញស្តីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ នៅថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងអន្តរជាតិ រួមទាំង JAG, HRF, NECA ជាដើម

# លទ្ធផលរំពឹងទុក

**លទ្ធផលរំពឹងទុកទី១**

ប្រព័ន្ធប្រកាសឱ្យដឹងមុន ១២៩៤ នឹងដំណើរការនៅក្នុងខេត្តគោលដៅថ្មីដែលងាយរងគ្រោះដោយគ្រោះមហន្តរាយ ដោយផ្អែកលើការតាមដានកម្រិតទឹកក្រោមដី និងលើដីដែលត្រូវបានធ្វើបច្ចុប្បន្នភាពឱ្យដំណើរការប្រសើរឡើង

**លទ្ធផលរំពឹងទុកទី២**

ភាគីពាក់ព័ន្ធមកពីក្រសួងអភិវឌ្ឍន៍ជនបទ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានសមត្ថភាពគ្រប់គ្រងប្រព័ន្ធប្រកាសឱ្យដឹងមុន ១២៩៤

**លទ្ធផលរំពឹងទុកទី៣**

ក្រុមងាយរងគ្រោះ (រាប់បញ្ចូលទាំង ស្ត្រី យុវជន និងអនក្ខរជន) នៅក្នុងខេត្តគោលដៅថ្មីដែលងាយរងគ្រោះដោយគ្រោះមហន្តរាយ អាចទទួលបានព័ត៌មានប្រុងប្រយ័ត្នពីគ្រោះមហន្តរាយតាមរយៈប្រព័ន្ធប្រកាសឱ្យដឹងមុន១២៩៤ និងប្រើប្រាស់ប្រព័ន្ធនេះក្នុងការទទួលបានព័ត៌មានប្រកាសឱ្យដឹងមុន និងរាយការណ៍អំពីការបាត់បង់ និងការខូចខាតប្រកបដោយប្រសិទ្ធភាព

**លទ្ធផលរំពឹងទុកទី៤**

វេទិកាសម្របសម្រួលជាប្រចាំក្នុងការចែករំលែកអំពីប្រព័ន្ធប្រកាសឱ្យដឹងមុនជាមួយក្រសួងពាក់ព័ន្ធ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងអង្គការដៃគូក្រៅរដ្ឋាភិបាល

# គោលបំណង

ប្រជាសហគមន៍ រួមមានក្រុមងាយរងគ្រោះ (ស្ត្រី យុវជន និងអនក្ខរជន)នៅក្នុងខេត្តគោលដៅដែលងាយរងគ្រោះដោយគ្រោះមហន្តរាយ ឆ្លើយតបលើព័ត៌មានដែលទទួលបានតាមរយៈប្រព័ន្ធប្រកាសឱ្យដឹងមុន ១២៩៤

ភាគីពាក់ព័ន្ធរួមមានរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលអាចសម្របសម្រួលក្នុងការងារការត្រៀមខ្លួននិងឆ្លើយតបទៅនឹងគ្រោះមហន្តរាយបានប្រសើរជាងមុន

ប្រជាសហគមន៍រួមមានក្រុមងាយរងគ្រោះ(ស្ត្រី យុវជន និងអនក្ខរជន)នៅក្នុងខេត្តគោលដៅដែលងាយរងគ្រោះដោយគ្រោះមហន្តរាយ បានកាត់បន្ថយការខូចខាត

**ផលជះរយៈពេលវែង**


**អង្គការអាក់សិនអេតកម្ពុជា**
ផ្ទះលេខ៣៣ ផ្លូវលេខ៧១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
លេខទំនាក់ទំនង៖ ០២៣ ២១១ ៤៦២
អ៊ីម៉ែល៖ e-mail.cambodia@actionaid.org


ស្កេនទីនេះ

Ground Water Level Monitoring

Tepmacha sensors